## **ការណែនាំ**

### **របៀបំពេញថវិកានេះ៖**

ទម្រង់គំរូនេះ មានបំណងក្តោបរាល់តម្លៃគម្រោង *ទាំងមូល* រួមទាំងតម្លៃដែលនឹងត្រូវទូទាត់ពីប្រាក់ជំនួយដែលបានកម្មវិធីភាពធន់សេដ្ឋកិច្ច និងប្រភពផ្សេងៗទៀតបើមាន។ បើលោកអ្នកបានបង្កើតថវិកានេះរួចទៅហើយ លោកអ្នកអាចដាក់វាជំនួសការបំពេញទម្រង់គំរូនេះ បើឯកសារនោះមានបញ្ចូលរាល់ព័ត៌មានដូចដែលបានស្នើសុំក្នុងទម្រង់គំរូនេះ។

Box 1: សូមកត់រាល់ចំណុចនីមួយនៃគម្រោងនេះ។ បើចំណុចទាំងនេះ ឬទំនាក់ទំនងរបស់វាទៅនឹងគម្រោង បង្កើតឲ្យមានភាពមិនច្បាស់លាស់ចំពោះអ្នកដែលមិនដឹងអំពីគម្រោងនេះ សូមផ្តល់សេចក្តីពន្យល់ផង នៅក្នុង Box 1។ បើលោកអ្នកមានចំណុចច្រើនជាងកន្លែងដែលសរសេរក្នុងមួយទំព័រនោះ សូមសរសេរបន្ថែមទំព័របើចាំបាច់។

Box 2: បើចំណុចនៃថវិកា ជាផ្នែកនៃសំណើសុំថវិកាជំនួយផ្នែកភាពធន់សេដ្ឋកិច្ចរបស់លោកអ្នក សូមបញ្ចូលចំនួនប៉ាន់ស្មានក្នុង Box 2។ បើលោកអ្នក មិនស្នើសុំមូលនិធិភាពធន់សេដ្ឋកិច្ចក្នុងពេលនេះទេ សូមទុកប្រអប់នោះទំនេរ។

Box 3: បើចំណុចនៃថវិកា ត្រូវផ្តល់ជូនដោយប្រភពផ្សេង ដូចជាថវិកាមូលធនរបស់លោកអ្នក ឬជំនួយថវិកាផ្សេង សូមកត់ចំនួននោះ និងប្រភពនៅទីនេះ។ សូមកុំ ដាក់សំណើសុំជំនួយថវិកាភាពធន់សេដ្ឋកិច្ច នៅក្នុងប្រអប់នេះ។ បន្ទាប់មក សូមគូសក្នុងប្រអប់នោះ ដើម្បីបញ្ជាក់ថាមូលនិធិនោះត្រូវបានធានាហើយ ឬកំពុងរង់ចាំចម្លើយ។ មូលនិធិដែល "ត្រូវបានធានាហើយ" មានន័យថាជាមូលនិធិ ដែលគេសន្យាផ្តល់ឲ្យអង្គការរបស់លោកអ្នក ឬផ្តល់ឲ្យគម្រោង។ ឧទាហរណ៍ ថវិការបស់លោកអ្នក ប្រហែលអាចមានចំណុចពិសេសសម្រាប់គម្រោងនេះ ឬលោកអ្នកទទួលបានលិខិតសន្យាផ្តល់ថវិកា។ "រង់ចាំចម្លើយ" មានន័យថា មូលនិធិមិនទាន់ត្រូវបានសន្យាថាឲ្យនៅឡើយ។ ឧទាហរណ៍ ចំណុចនេះអាចបូកបញ្ចូលទាំងថវិកាជំនួយ ឬ កម្ចីដែលអ្នកដាក់ពាក្យសុំ ឬអនុសាសន៍ថវិកាមូលធន។

Box 4: សរុបចំណុចនីមួយ ដូចដែលបានស្នើ ដោយបន្ថែមចំនួនដែលមានក្នុង Box 2 និង Box 3។

Box 5: សូមបញ្ចូលរាល់ចំណុចនីមួយៗនៃថវិកាជំនួយផ្នែកភាពធន់សេដ្ឋកិច្ច។ ចំនួននេះ ត្រូវតែស៊ីគ្នាទៅនឹងចំនួនដែលបានស្នើក្នុងចំនុច Question 10 នៃពាក្យសុំនេះ។ បើវាមិនស៊ីគ្នាទេ សំណើរបស់លោកអ្នក នឹងត្រូវចាត់ទុកថាទាបជាងកម្រិតនៃតួលេខទាំងពីរនោះ។

Box 6: សូមបូកបញ្ចូលគ្នារាល់ចំនួននៃមូលនិធិទាំងអស់។

Box 7: សូមបូកបញ្ចូលចំនួននៅក្នុង Box 5 + Box 6 សម្រាប់ថវិកាសរុបរបស់លោកអ្នក

**ឧទាហរណ៍នៃសំណើត្រឹមត្រូវតាមផ្នែក។** សូមកត់សម្គាល់ ថាបញ្ជីនេះមិនមែនជាបញ្ជីពិស្តារនោះឡើយ ដូច្នេះយើងលើកទឹកចិត្តឲ្យលោកអ្នកចេះច្នៃប្រឌិត។

- **ការបង្កើតទីធ្លា៖** តម្លៃរចនា ពលកម្ម គ្រឿងសង្ហារឹមខាងក្រៅអគារ ការដាំដើមឈើ។
- **ការបង្កើតកម្មវិធី៖** សម្ភារ: ការផ្សាយពាណិជ្ជកម្ម ឧបករណ៍ធុនតូច ថ្លៃប្រាក់ខែសម្រាប់បុគ្គលិកថ្មី ឬសម្រាប់កម្មវិធីថ្មីដែលបង្កើនថ្លៃចំណាយលើប្រាក់ខែ ដែលលើសពីចំនួនដែលមានស្រាប់។
- **ទីតាំង និងហេដ្ឋារចនាសម្ព័ន្ធ៖** ឧបករណ៍ធំ សម្ភារ:សំណង់ សម្ភារ:អចិន្ត្រៃយ៍ ឬពាក់កណ្តាលអចិន្ត្រៃយ៍ ដែលដោះស្រាយបញ្ហាសុខភាពសាធារណ: បរិស្ថាន ឬ ដំណោះស្រាយការធ្វើដំណើរចេញចូលសម្រាប់ជនពិការ ថ្លៃសាងសង់ ការសិក្សាអំពីផលប៉ះពាល់ ថ្លៃរចនា។

### **របៀបដាក់ថវិកានេះ៖**

ថវិកានេះនឹងត្រូវដាក់ជាមួយពាក្យសុំតាមអនឡាញជាបឋមរបស់លោកអ្នក។ លោកអ្នកនឹងដាក់វាត្រង់ Question 12។